# ១. ប្រតិបត្តិសង្ខេប

នៅខែមករាឆ្នាំ ២០១៧ រដ្ឋាភិបាលកម្ពុជាបានផ្តួចផ្តើមយុទ្ធនាការ ៦ ខែប្រឆាំងនឹងគ្រឿងញៀន ដែលត្រូវបានបន្តធ្វើម្តងហើយម្តងទៀតនិងមិនកំណត់ចាប់តាំងពីពេលនោះមក។  យុទ្ធនាការនេះ ដែលត្រូវបានគេសង្កេតឃើញយ៉ាងហោចណាស់មានមនុស្សចំនួន ៥៥,៧៧០ នាក់ត្រូវបានចាប់ខ្លួនពីបទសង្ស័យប្រើប្រាស់ ឬលក់គ្រឿងញៀន នៅចន្លោះខែមករា ឆ្នាំ២០១៧ និងខែមីនា ឆ្នាំ២០២០ ត្រូវបានបន្តធ្វើម្តងហើយម្តងទៀត និងធ្វើមិនកំណត់ពេល ចាប់តាំងតែពីពេលនោះមក។[1]

រហូតមកដល់បច្ចុប្បន្ន យុទ្ធនាការនេះបានសង្កត់ធ្ងន់លើសលប់លើការឃុំខ្លួននិងការនាំខ្លួនទៅកាត់ទោស - ជាជាងការធានាឱ្យមានការថែទាំសុខភាពគ្រប់គ្រាន់សម្រាប់អ្នកដែលប្រើប្រាស់គ្រឿងញៀន រួមទាំងការព្យាបាល ការស្តារនីតិសម្បទា និងការកាត់បន្ថយគ្រោះថ្នាក់ - បាននាំឱ្យមានវិបត្តិសុខភាពសាធារណៈនិងសិទ្ធិមនុស្សកាន់តែធ្ងន់ធ្ងរឡើង។

ក្នុងរយៈពេលបីឆ្នាំ ចាប់តាំងពីការចាប់ផ្តើមយុទ្ធនាការប្រឆាំងនឹងគ្រឿងញៀនរបស់ប្រទេសនេះ វាមិនត្រឹមតែបានបរាជ័យនៅក្នុងបេសកកម្មចម្បងរបស់ខ្លួនក្នុងការកាត់បន្ថយការប្រើប្រាស់គ្រឿងញៀននិងគ្រោះថ្នាក់ទាក់ទងនឹងគ្រឿងញៀនប៉ុណ្ណោះទេ វាបាននាំឱ្យមានការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ និងមានលក្ខណៈជាប្រព័ន្ធថែមទៀត។ អ្នកស្រី ណារ៉ាន់ អាយុ៤១ ឆ្នាំជាអ្នកប្រើប្រាស់សេវាមេតាដូន ដោយឆ្លុះបញ្ចាំងពីបទពិសោធន៍របស់គាត់ ក្នុងយុទ្ធនាការប្រឆាំងគ្រឿងញៀន បានប្រាប់អង្គការលើកលែងទោសអន្តរជាតិថា “ជាអ្នកប្រើគ្រឿងញៀន ត្រូវបានគេប្រព្រឹត្តមកលើខ្លួនដូចជាសត្វអញ្ចឹង។” [2]

របាយការណ៍នេះផ្អែកលើការចុះស្រាវជ្រាវតាមមូលដ្ឋាន ដែលអនុវត្តដោយអង្គការលើកលែងទោសអន្តរជាតិ ក្នុងខែវិច្ឆិកានិងខែធ្នូឆ្នាំ២០១៩ ចងក្រងឯកសារស្តីពីការរំលោភសិទ្ធិមនុស្សយ៉ាងរីករាលដាល ពាក់ព័ន្ធនឹងយុទ្ធនាការប្រឆាំងគ្រឿងញៀនរបស់រដ្ឋាភិបាលកម្ពុជា។ ភាគច្រើននៃមនុស្សដែលត្រូវបានសម្ភាសដោយអង្គការលើកលែងទោសអន្តរជាតិ - ជាពិសេសមនុស្សដែលត្រូវបានចាប់ខ្លួន និងឃុំខ្លួន ជាផ្នែកមួយនៃយុទ្ធនាការ រួមទាំងសមាជិកគ្រួសាររបស់ពួកគេផង គឺមកពីសហគមន៍ក្រីក្រ និងដែលងាយទទួលរងការម៉ាក់ងាយ។

មនុស្សដែលអង្គការលើកលែងទោសអន្តរជាតិបានសម្ភាសន៍ ត្រូវបានគេឃុំខ្លួនក្រោមប្រព័ន្ធមួយក្នុងចំណោមប្រព័ន្ធពីរទន្ទឹមគ្នានៃការឃុំខ្លួននិងផ្តន្ទាទោសគឺៈ ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឬការឃុំខ្លួនបែបរដ្ឋបាលទាក់ទងនឹងគ្រឿងញៀន។ ការផ្តន្ទាទោសព្រហ្មទណ្ឌ ដែលចងក្រងដោយអង្គការលើកលែងទោសអន្តរជាតិ ត្រូវបានញាំញីដោយការរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងអំពើពុករលួយ។ សម្រាប់បុគ្គលមកពីសហគមន៍ក្រីក្រនិងសហគមន៍ដែលងាយរងការម៉ាក់ងាយ ដោយគ្រាន់តែជាអ្នកឈរក្បែរកន្លែងខុស នៅពេលខុស ឬការធ្វើតេស្តវិជ្ជមានដោយការធ្វើតេស្តគ្រឿងញៀនដោយបង្ខំ អាចនាំឱ្យជាប់ពន្ធនាគារជាច្រើនឆ្នាំ សូម្បីតែនៅពេលខ្លះ ស្ថិតក្រោមការចោទប្រកាន់ពីបទជួញដូរគ្រឿងញៀន។ សម្រាប់បុគ្គលមកពីសហគមន៍ក្រីក្រនិងសហគមន៍ដែលងាយរងការម៉ាក់ងាយ ដោយគ្រាន់តែជាអ្នកឈរក្បែរកន្លែងខុស នៅពេលខុស ឬការធ្វើតេស្តវិជ្ជមានដោយការធ្វើតេស្តគ្រឿងញៀនដោយបង្ខំ អាចនាំឱ្យជាប់ពន្ធនាគារជាច្រើនឆ្នាំ សូម្បីតែនៅពេលខ្លះស្ថិតក្រោមការចោទប្រកាន់ពីបទជួញដូរគ្រឿងញៀន។

ក្នុងករណីខ្លះ ជនរងគ្រោះបានប្រាប់អង្គការលើកលែងទោសអន្តរជាតិថា ពួកគេត្រូវបានបង្ខំឱ្យ “សារភាព” ក្រោមការធ្វើទារុណកម្មនិងការធ្វើបាបផ្សេងទៀត។ កាលណាត្រូវគេចោទប្រកាន់ពីបទល្មើសទាក់ទងនឹងគ្រឿងញៀន ជនជាប់ចោទដែលក្រីក្រនិងដែលងាយរងការម៉ាក់ងាយ ត្រូវប្រឈមនឹងការសន្មតថាមានពិរុទ្ធភាព ដែលស្ទើរតែមិនអាចយកឈ្នះបាន។ ស្រីនាង ជាស្ត្រីវ័យ ៣០ ឆ្នាំមកពី

1 អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន របាយការណ៍ពេញប្រចាំឆ្នាំ២០១៧ ចុះថ្ងៃទី២៦ ខែកុម្ភៈឆ្នាំ ២០១៨; អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន របាយការណ៍ពេញប្រចាំឆ្នាំ២០១៨ ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៨; អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន របាយការណ៍ឆមាសទី១ ឆ្នាំ២០១៩ ចុះខែវិច្ឆិកា ឆ្នាំ២០១៩; ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ដោយលោក យុត សុភ័ក្រចរិយា“ មនុស្សជាង ៥,៥០០ នាក់ត្រូវបានចាប់ខ្លួនពីបទគ្រឿងញៀន” ។ https://www.phnompenhpost.com/national/over-5500-arrested-drugs (ចូលមើលចុងក្រោយ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០) ។

2 អង្គការលើកលែងទោសអន្តរជាតិ សម្ភាសន៍ជាមួយ អ្នកស្រីណារ៉ាន់ នៅរាជធានីភ្នំពេញ ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៩។

រាជធានីភ្នំពេញ បានរៀបរាប់ពីរបៀបដែលនាងត្រូវបានគេធ្វើទារុណកម្ម បន្ទាប់ពីការចាប់ខ្លួនតាមអំពើចិត្តមកលើនាង ក្នុងអំឡុងពេលនៃការឆ្មក់ចូលទាក់ទងនឹងគ្រឿងញៀននៅភ្នំពេញ ៖

> **“ពួកគេបានសួរខ្ញុំថាតើខ្ញុំលក់គ្រឿងញៀនបានប៉ុន្មានដង... មន្ត្រីប៉ូលីស និយាយថា បើខ្ញុំមិនសារភាពទេ គាត់នឹងកាំភ្លើងឆក់លើខ្លួនខ្ញុំម្តងទៀត។**
>
> ស្រីនាង ត្រូវបានផ្តន្ទាទោសពីបទជួញដូរនិងជាប់ពន្ធនាគារក្នុងមណ្ឌល់អប់រំកែប្រែទី២ របស់រាជធានីភ្នំពេញ។

បន្ទាប់ពីចំណាយពេល ៦ ខែ ក្នុងស្ថានភាពអមនុស្សធម៌ ក្នុងការឃុំខ្លួនមុនការជំរះក្តី រួមជាមួយកូនប្រុសរបស់នាង ស្រីនាងត្រូវបានកាត់ឱ្យជាប់ពិរុទ្ធ ក្រោយពីការជំនុំជម្រះអយុត្តិធម៌មួយ ហើយត្រូវបានគេផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេល ២.៥ ឆ្នាំ ពីបទជួញដូរគ្រឿងញៀន។ នាងបានរំឭកអំពីសាលក្រមនេះថា៖ “ខ្ញុំគិតចង់ធ្វើអត្តឃាតនៅពេលនេះដោយលេបថ្នាំ។ តែក្រោយមក ខ្ញុំគិតអំពីកូនៗរបស់ខ្ញុំ តើនឹងមានអ្វីកើតឡើងចំពោះពួកគេបើគ្មានរូបខ្ញុំ។”

បទពិសោធន៍របស់ស្រីនាង គឺជាចរិតលក្ខណៈនៃយុទ្ធនាការប្រឆាំងគ្រឿងញៀននៅកម្ពុជា។ គ្រប់ករណីទាំងអស់ ដែលបានកត់ត្រាជាឯកសារដោយអង្គការលើកលែងទោសអន្តរជាតិ បង្ហាញថាជនជាប់ចោទត្រូវបានគេដាក់ឱ្យជាប់ពិរុទ្ធភាព ហើយម្នាក់ៗបានពិពណ៌នាអំពីការសវនាកា ដែលមិនមានស្មើភាពគ្នានៃយុត្តិធម៌ បានកំណត់តែខ្លួនឯងថាបានបំពេញទៅតាមបទដ្ឋានអន្តរជាតិនៃការជំនុំជម្រះដោយយុត្តិធម៌។ យោងទៅតាមមនុស្សដែលអង្គការបានសម្ភាស មិនមានឱកាសណាមួយទទួលបានការធានាឱ្យនៅក្រៅឃុំ ឬបានទទួលជម្រើសពីការមិនឃុំឃាំងខ្លួនផ្សេងទៀត ក្រៅពីការប្រើប្រាស់ការឃុំខ្លួនមុនការជម្រះក្តី ឬសូម្បីតែពិចារណាឱ្យបានច្បាស់លាស់ក៏គ្មានដែរ។ គ្មាននរណាម្នាក់ក្នុងចំណោមអ្នកដែលត្រូវបានសម្ភាស ទទួលបានការយល់ដឹងអំពីសិទ្ធិរបស់ពួកគេទេហើយមានតែចុងចោទពីរនាក់ប៉ុណ្ណោះ ដែលត្រូវបានផ្តល់ជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ។

ជនជាប់ចោទក្រីក្រតិចតួច ក្នុងយុទ្ធនាការប្រឆាំងគ្រឿងញៀននៅកម្ពុជា មានលទ្ធភាពទទួលបានមេធាវី ដោយភាគច្រើនខកខានមិនទទួលបានកម្រិតខ្ពស់សម្រាប់ជំនួយផ្នែកច្បាប់ឥតគិតថ្លៃនោះឡើយ។ នៅពេលពួកគេត្រូវបានគេដាក់ឱ្យជាប់ពិរុទ្ធ - ជាអ្វីដែលពួកគេស្ទើរតែជៀសមិនរួច - ពួកគេប្រឈមមុខនឹងការនៅក្នុងគុកច្រើនឆ្នាំ ដែលជាគុកដ៏ចង្អៀតណែន ដែលពោរពេញដោយជំងឺ។

> **អតីតអ្នកទោសម្នាក់បានរំឭកថា ៖ “ប្រសិនបើមនុស្សម្នាក់ឆ្លងមេរោគផ្លូវដង្ហើមនោះក្នុងរយៈពេលពីរបីថ្ងៃ អ្នករាល់គ្នានៅក្នុងបន្ទប់ឃុំខ្លួន នឹងឆ្លងជំងឺនេះ។ វាជាកន្លែងបង្កាត់ពូជជំងឺ។** [3]
>
> ឡុង អតីតអ្នកជាប់ឃុំមណ្ឌលអប់រំកែប្រែទី១របស់រាជធានីភ្នំពេញ។

យុទ្ធនាការប្រឆាំងគ្រឿងញៀន មានផលប៉ះពាល់មិនសមាសមាត្រ និងមានចរិតរើសអើងលើស្ត្រី កុមារ និងប្រជាពលរដ្ឋដែលមកពីក្រុមងាយរងការម៉ាក់ងាយ រួមទាំងអ្នករស់នៅជាមួយមេរោគអេដស៍ផងដែរ។ ៧៣% នៃអ្នកទោសជាស្ត្រីទាំងអស់នៅកម្ពុជា ឥឡូវត្រូវបានជាប់ពន្ធនាគារក្រោមការចោទប្រកាន់ពាក់ព័ន្ធនឹងគ្រឿងញៀន។

អ្នកស្រី ម៉ាលី អាយុ ៤០ ឆ្នាំ បានរៀបរាប់លម្អិតពីការលំបាកក្នុងការចិញ្ចឹមកូនរបស់នាងក្នុងស្ថានភាពដ៏ចង្អៀតណែននៅក្នុងមណ្ឌលអប់រំកែប្រែទី២ ដូច្នេះថា ៖ “វាលំបាកណាស់ក្នុងការចិញ្ចឹមកូនស្រីរបស់ខ្ញុំ។ នាងចង់ផ្លាស់ទីជុំវិញនាង ចង់បានទីធ្លាបន្ថែម នាងចង់ឃើញខាងក្រៅ។ នាងចង់បានសេរីភាព ... នាងតែងតែមានជំងឺគ្រុនក្តៅនិងផ្តាសាយ។ ដោយសារតែយើងអត់មានទីធ្លា ដូច្នេះកូនរបស់ខ្ញុំដេកនៅលើដងខ្លួនរបស់ខ្ញុំ។[4]

[3] អង្គការលើកលែងទោសអន្តរជាតិ សម្ភាសន៍ជាមួយបុរសម្នាក់ ដែលត្រូវបានឃុំខ្លួនក្នុងកំឡុងពេលយុទ្ធនាការប្រឆាំងគ្រឿងញៀន តាមរយៈទូរស័ព្ទថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២០ ។
[4] អង្គការលើកលែងទោសអន្តរជាតិ សម្ភាសន៍ជាមួយអ្នកស្រីម៉ាលី នៅរាជធានីភ្នំពេញថ្ងៃទី១៦ ខែវិច្ឆិកាឆ្នាំ២០១៩ ។

ជំនួសឱ្យការចាប់នាំខ្លួនពីបទព្រហ្មទណ្ឌ មនុស្សរាប់ពាន់នាក់ជារៀងរាល់ឆ្នាំ ត្រូវបានគេឃុំខ្លួនដោយគ្មានបទចោទប្រកាន់ នៅក្នុងមណ្ឌល "ស្តារនីតិសម្បទា" គ្រឿងញៀន និង មជ្ឈមណ្ឌល "សង្គមកិច្ច" (ដែលហៅថា មជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀន)។ អតីតអ្នកជាប់ឃុំនៅមន្ទីរឃុំឃាំងគ្រឿងញៀន បានពិពណ៌នាអំពីស្ថានភាពអមនុស្សធម៌ច្រើនជាងអ្វីៗដែលគេបានរកឃើញនៅក្នុងប្រព័ន្ធពន្ធនាគារ។ ទោះបីមណ្ឌលទាំងនេះ អះអាងព្យាបាលមនុស្សដែលញៀនញៀនក៏ដោយ តាមពិតមណ្ឌលនេះ ដំណើរការជាមជ្ឈមណ្ឌលឃុំឃាំងបែបដាក់ទណ្ឌកម្ម និងបែបរំលោភបំពាន ដែលជាកន្លែងខ្វះខាតយ៉ាងអាក្រក់ខាងផ្នែកវេជ្ជសាស្ត្រ និងខ្វះបុគ្គលិកដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ។

ជាជាងទទួលការព្យាបាលផ្អែកលើភ័ស្តុតាង អ្នកជាប់ឃុំត្រូវបានឃុំខ្លួនប្រឆាំងនឹងឆន្ទៈរបស់ពួកគេ ហើយប្រឈមនឹងការរំលោភបំពានជាប្រព័ន្ធ។ ដូចអតីតអ្នកជាប់ឃុំម្នាក់បានរៀបរាប់ថា៖

> **"នៅទីនោះ ខ្ញុំមានអារម្មណ៍ថាខ្ញុំស្ថិតនៅក្នុងនរក។ ដោយព្យាយាមស៊ូទ្រាំការវាយដំ ជាមួយអាហារ ការចង្អៀតណែន ពិតជាមិនអាចទ្រាំទ្របានមែន" ។ [5]**
>
> រដ្ឋា អតីតអ្នកជាប់ឃុំ ក្នុងមណ្ឌលឃុំឃាំងព្រៃស្ពឺ រាជធានីភ្នំពេញ។

មណ្ឌលឃុំឃាំងគ្រឿងញៀនរបស់ប្រទេសកម្ពុជា បានប្រឈមមុខនឹងការរិះគន់ជាបន្តបន្ទាប់ រាប់បញ្ចូលទាំងការចោទប្រកាន់អំពីការធ្វើទារុណកម្ម ពលកម្មដោយបង្ខំ អំពើហិង្សាផ្លូវភេទ និងការស្លាប់នៅក្នុងការឃុំឃាំង។[6] ទោះបីមានការព្រួយបារម្ភជាច្រើន ដែលបានលើកឡើងពីយន្តការសិទ្ធិមនុស្សអន្តរជាតិ និងពីអង្គការសង្គមស៊ីវិលក៏ដោយ ក៏ភាពប្រសើរឡើងមានតែបន្តិចបន្តួច ឬគ្មានធ្វើឱ្យប្រសើរឡើងទាល់តែសោះ នៅក្នុងការតាមដាន និងគ្រប់គ្រងកន្លែងឃុំឃាំងទាំងនេះ ហើយរបាយការណ៍អំពីការរំលោភសិទ្ធិមនុស្សនៅតែបន្តកើតមាន។

អ្នកទាំងឡាយដែលសម្ភាសន៍ដោយអង្គការលើកលែងទោសអន្តរជាតិ គឺជាអ្នកដែលត្រូវបានបញ្ជូនទៅមណ្ឌលឃុំឃាំងគ្រឿងញៀន និងដែលត្រូវបានគេឃុំខ្លួនដោយមិនមានការស្ម័គ្រចិត្តហើយគ្មាននរណាម្នាក់ ត្រូវបានផ្តល់សិទ្ធិទទួលបានមេធាវីនោះទេ។ ស្ទើរតែគ្មាននរណាម្នាក់ត្រូវបានគេនាំទៅចំពោះមុខចៅក្រម ឬតុលាការឡើយ។ គ្រប់បុគ្គលដែលសម្ភាសន៍ដោយអង្គការលើកលែងទោសអន្តរជាតិ បានផ្តល់នូវរបាយការណ៍លំអិតស្តីពីការរំលោភបំពានលើរាងកាយ ជាបែបផែននៃការធ្វើទារុណកម្ម ឬការធ្វើបាបដទៃទៀត ដែលប្រព្រឹត្តដោយបុគ្គលិកមជ្ឈមណ្ឌល ឬជាអ្វីដែលគេហៅថា "មេបន្ទប់" - ជាអ្នកទោសដូចគ្នា ដែលបុគ្គលិកមណ្ឌលប្រគល់នាទីឱ្យអនុវត្តវិន័យ។

ប្រជាពលរដ្ឋដែលធ្លាប់ត្រូវបានឃុំខ្លួននៅក្នុងមណ្ឌលទាំងនេះ បានពិពណ៌នាអំពីរបបនៃការរំលោភបំពានដ៏ឃោរឃៅ ដែលពួកគេបានជួបប្រទះនៅក្នុងលក្ខខណ្ឌលម្អិតនិងជាក់ស្តែង។ សារ៉ាត់ ដែលមានអាយុ ១៧ ឆ្នាំ នៅពេលដែលគាត់ជាប់ឃុំនៅព្រៃស្ពឺ ភ្នំពេញ បានរំឭកអំពីការមកដល់របស់គាត់នៅឯមជ្ឈមណ្ឌលនេះ ៖ "នៅពេលដែលអ្នកយាមចាកចេញ មេបន្ទប់បានចាប់ផ្តើមវាយខ្ញុំ។ ខ្ញុំត្រូវគេវាយសន្លប់ ដូច្នេះខ្ញុំមិនអាចចាំពីអ្វីដែលបានកើតឡើង ក្រោយពីនោះមកទេ។" [7]

អង្គការលើកលែងទោសអន្តរជាតិ ទទួលបានការចោទប្រកាន់ដោយគ្មានភស្តុតាងជាច្រើនអំពីការស្លាប់នៅក្នុងមណ្ឌលឃុំឃាំងព្រៃស្ពឺ និងឱកាសខ្ញុំ នៅរាជធានីភ្នំពេញ។ លោកផានិត អតីតមេបន្ទប់ ពីមជ្ឈមណ្ឌលឱកាសខ្ញុំ បានរំឭកពីការស្លាប់របស់អ្នកជាប់ឃុំកាលពីខែមីនា ឆ្នាំ២០១៨ ដូច្នេះថា ៖

[5] អង្គការលើកលែងទោសអន្តរជាតិ សម្ភាសន៍ជាមួយរដ្ឋា នៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ ២០១៩។
[6] គណៈកម្មាធិការប្រឆាំងអំពើទារុណកម្មរបស់អង្គការសហប្រជាជាតិ ការសង្កេតស្ថិដ្ឋានរបស់គណៈកម្មាធិការប្រឆាំងនឹងទារុណកម្ម - កម្ពុជា ខែមករា ឆ្នាំ២០១១, ឯកសារអង្គការសហប្រជាជាតិ CAT/C/KHM/CO/2, para. 18-20; គណៈកម្មាធិការដើម្បីសិទ្ធិកុមារ (CRC); សេចក្តីអង្កេតសន្និដ្ឋាន៖ ប្រទេសកម្ពុជា ខែសីហា ឆ្នាំ២០១១ CRC/C/KHM/CO/2-3, para. 38-39; គណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (CESCR), សេចក្តីសង្កេតស្ថិដ្ឋានរបស់គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ - កម្ពុជា ខែមិថុនា E/C.12/KHM/CO/1, para. 33; អង្គការសុខភាពពិភពលោក (WHO),"ការវាយតម្លៃការព្យាបាលដោយបង្ខំលើអ្នកដែលប្រើប្រាស់គ្រឿងញៀននៅកម្ពុជា ចិន ម៉ាឡេស៊ី និងវៀតណាម" ឆ្នាំ២០០៩; អង្គការឃ្លាំមើលសិទ្ធិមនុស្ស "ស្បែកដាច់ជាប់ខ្សែភ្លើង៖ ការចាប់ខ្លួនដោយខុសច្បាប់ ការឃុំឃាំងតាមអំពើចិត្តនិងទារុណកម្មលើអ្នកប្រើប្រាស់គ្រឿងញៀននៅកម្ពុជា" ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១០។ https://www.hrw.org/report/2010/01/25/skin-cable/illegal-arrest-arbitrary-detention-and-torture-people-who-use-drugs (ចូលមើលចុងក្រោយ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០); អង្គការឃ្លាំមើលសិទ្ធិមនុស្ស "ពួកគេប្រព្រឹត្តមកលើយើងដូចជាសត្វ ៖ ការធ្វើបាបអ្នកប្រើគ្រឿងញៀននិង "អំពើដែលមិនត្រូវការ" នៅក្នុងមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀននៅកម្ពុជា ឆ្នាំ២០១៣ https://www.hrw.org/sites/default/files/reports/cambodia1213_ForUpload_1.pdf (ចូលមើលចុងក្រោយ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០); អង្គការលីកាដូ និងអង្គការឃ្លាំមើលសិទ្ធិមនុស្ស "ការស្លាប់នៅព្រៃស្ពឺ បង្ហាញពីការរំលោភបំពានរបស់មជ្ឈមណ្ឌលឃុំឃាំង" ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៤, http://www.licadho-cambodia.org/pressrelease.php?perm=365 (ចូលមើលចុងក្រោយ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០); អង្គការលីកាដូ" មណ្ឌលឃុំខ្លួនព្រៃស្ពឺ គួរតែបិទចោល ដើម្បីផលល្អ" ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៦, http://www.licadho-cambodia.org/articles/20160608/147/index.html (ចូលមើលចុងក្រោយ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០); អង្គការលីកាដូ "លិខិតចំពោះនិពន្ធនាយក៖ រដ្ឋាភិបាលត្រូវតែបិទព្រៃស្ពឺ" ខែកក្កដា ឆ្នាំ២០១០។ http://www.licadho-cambodia.org/reports.php?perm=198 (ចូលមើលចុងក្រោយ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០) ។
[7] អង្គការលើកលែងទោសអន្តរជាតិ សម្ភាសន៍ជាមួយសារ៉ាត់ នៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០១៩។

**មនុស្សដែលញៀនខ្លាំងមែនទែន ត្រូវតែដាក់ច្រវាក់ដោយដៃនិងជើង ដើម្បីកុំឱ្យគាត់រើទៅណាបាន។ ហើយមេអាគារ បានវាយគាត់បែបហ្នឹង រហូតដល់គាត់ស្លាប់... ។ ពួកគេបានព្យាយាមបិទបាំងករណីនេះបន្ទាប់ពីនោះ។ ការលាយវាយដំ ការធ្វើទារុណកម្ម និងការញៀន គឺជាអ្វីដែលបានសម្លាប់គាត់។**[8]

ផានិត អតីត "មេបន្ទប់" នៅមណ្ឌលឃុំឃាំងគ្រឿងញៀនឱកាសខ្ញុំ។

កម្រិតអមនុស្សធម៌នៃចំនួនមនុស្សដ៏ចង្អៀតណែន ដែលបង្កឡើងដោយយុទ្ធនាការប្រឆាំងគ្រឿងញៀនរបស់រដ្ឋាភិបាល កំពុងតែញាំញីទាំងពន្ធនាគាររបស់ប្រទេស និងទាំងមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនរបស់ខ្លួន។ ចំនួនអ្នកទោសនៅកម្ពុជា បានហក់ឡើងខ្ពស់ខ្លាំងដល់ទៅចំនួន ៧៨% ចាប់តាំងពីយុទ្ធនាការនេះបានចាប់ផ្តើម គឺចាប់ពីចំនួន ២១,៩០០នាក់ នៅចុងឆ្នាំ ២០១៦ ដល់ចំនួនជាង ៣៨,៩៩០ នៅខែមីនា ឆ្នាំ២០២០ ទោះបីពន្ធនាគារនៅប្រទេសកម្ពុជាមានចំណុះប៉ាន់ស្មានត្រឹមតែ ២៦,៥៩៣ នាក់ក៏ដោយ។ នៅដើមឆ្នាំ២០២០ ចំនួនអ្នកទោសនៅក្នុងពន្ធនាគារដែលធំជាងគេបំផុតនៅកម្ពុជា គឺមណ្ឌលអប់រំកែប្រែទី២ ដែលមានចំនួនអ្នកទោសលើសដល់ទៅចំនួន ៩,៥០០ នាក់ ដែលស្មើនឹង ៤៦៣% នៃចំណុះអតិបរមារបស់ខ្លួនដែលមានត្រឹមតែ ២,០៥០ នាក់។[9]

វិបត្តិដ៏ចង្អៀតណែននេះ កំពុងបង្កឱ្យមានការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ និងជាលក្ខណៈជាប្រព័ន្ធលើសិទ្ធិរបស់អ្នកទោសក្នុងការទទួលបាននូវសុខភាពផ្លូវកាយនិងផ្លូវចិត្តដែលអាចទទួលយកបានកម្រិតខ្ពស់បំផុត ហើយក្នុងករណីខ្លះ មានរហូតដល់ការធ្វើទារុណកម្ម ឬការធ្វើបាបផ្សេងទៀត ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

ជាមួយនឹងការគំរាមកំហែងនៃការរីករាលដាលនៃកូវីត១៩ រដ្ឋាភិបាលខ្លះនៅលើពិភពលោកបានចាត់វិធានការយ៉ាងម៉ឺងម៉ាត់ ដើម្បីដោះលែងអ្នកទោសអហិង្សា និងអ្នកទោសស្ថិតក្នុងហានិភ័យ រួមទាំងមនុស្សដែលត្រូវបានគេឃុំខ្លួនដោយគ្មានមូលដ្ឋានច្បាប់គ្រប់គ្រាន់ផងដែរ។ ទោះបីមានកម្រិតចង្អៀតណែន នៅក្នុងមណ្ឌលឃុំឃាំងរបស់ខ្លួនក៏ដោយ ក៏រដ្ឋាភិបាលកម្ពុជាបានប្រឆាំងនឹងសកម្មភាពបង្ការបែបនេះ ដោយធ្វើការចាប់ខ្លួនក្រោមយុទ្ធនាការប្រឆាំងគ្រឿងញៀន ដែលមានការកើនឡើងជាក់ស្តែងនៅដើមឆ្នាំ២០២០នេះ។[10] បើគិតពីភាពបន្ទាន់នៃសុខភាពសាធារណៈនេះ វាមិនដែលមានភាពបន្ទាន់កាន់តែច្រើនសម្រាប់អាជ្ញាធរកម្ពុជា ក្នុងការដោះស្រាយវិបត្តិដ៏ចង្អៀតណែនរបស់ប្រទេសនេះ។[11]

មានជំរើសផ្សេងៗគ្នា ចំពោះវិធីសាស្ត្រតឹងរឹងរបស់រដ្ឋាភិបាលចំពោះគ្រឿងញៀន។ ជាការពិតជាតួនានានៅក្នុងរដ្ឋាភិបាលកម្ពុជា ជាពិសេស ក្រសួងសុខាភិបាលនាពេលថ្មីៗនេះ បានសង្កត់ធ្ងន់លើទិដ្ឋភាពសុខភាពសាធារណៈនៃយុទ្ធនាការប្រឆាំងគ្រឿងញៀន និងពង្រីកលទ្ធភាពទទួលបានការព្យាបាលគ្រឿងញៀនតាមសហគមន៍។[12] នៅឆ្នាំ២០១៩ រដ្ឋាភិបាលបានទទួលយកអនុសាសន៍មួយនៅឯក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដោយប្តេជ្ញាមិនដាក់ជាទោសឧក្រិដ្ឋនៃការប្រើប្រាស់និងការកាន់កាប់គ្រឿងញៀននោះទេ ហើយថាខ្លួនបានបង្កើតកន្លែងព្យាបាលគ្រឿងញៀនដោយស្ម័គ្រចិត្តតាមសហគមន៍ចំនួន ៤៣១ កន្លែងនៅទូទាំងប្រទេសថែមទៀត។[13] ការវិវត្តទាំងនេះ កំពុងតែសន្យាចំពោះទស្សនៈសិទ្ធិមនុស្ស ក៏ប៉ុន្តែ គំនិតផ្តួចផ្តើមបែបនេះ នឹងត្រូវបរាជ័យ ប្រសិនជាគ្មានការកែទម្រង់ជាមូលដ្ឋាននៃយុទ្ធនាការប្រឆាំងគ្រឿងញៀននៅកម្ពុជាទេនោះ។

8 អង្គការលើកលែងទោសអន្តរជាតិ សម្ភាសន៍ជាមួយផានិត នៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩ ។
9 ដោយលោក នីម ឆេង "ពន្ធនាគារព្រៃសលែងទទួលយកអ្នកជាប់ឃុំមុនការជម្រះក្តីហើយ ដើម្បីបន្ថយបន្ទុក" ភ្នំពេញប៉ុស្តិ៍ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២០ ។ https://www.phnompenhpost.com/national/prey-sar-prison-no-longer-accepting-pre-trial-detainees-ease-burden (ចូលមើលថ្ងៃទី ២០ ខែមេសាឆ្នាំ ២០២០)។

10 ដោយលោកឃុតសុភ័ក្រចរិយា " ជាង ៥,៥០០ នាក់ត្រូវបានចាប់ខ្លួនពីបទគ្រឿងញៀន" ភ្នំពេញ ប៉ុស្តិ៍ថ្ងៃទី ៦ ខែមេសា ឆ្នាំ ២០២០។
https://www.phnompenhpost.com/national/over-5500-arrested-drugs (ចូលមើលចុងក្រោយ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០) ។
11 សូមមើល៖ អង្គការលើកលែងទោសអន្តរជាតិ "ប្រទេសកម្ពុជា៖ មណ្ឌលឃុំឃាំងមនុស្សដ៏ចង្អៀតណែន ជាពេលនាំឲ្យមានការផ្ទុះនៃកូវីត១៩ ចំពេលមានការចាប់ខ្លួនលើការផ្សាយ "ព័ត៌មានក្លែងក្លាយ" នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ https://bit.ly/2UQ7klA
12 ដោយ គង់ មេត្តា "ការប្រជុំជំរុញឲ្យមានវិធីសាស្ត្រថ្មីៗដើម្បីស្តារនីតិសម្បទារ" កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦ https://www.phnompenhpost.com/national/meeting-touts-new-approach-rehab (ចូលមើលចុងក្រោយ ថ្ងៃ២០ ខែមេសា ឆ្នាំ២០២០)
13 អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀននិងឧក្រិដ្ឋកម្មរបាយការណ៍យុទ្ធនាការឆ្នាំ២០១៨-២០១៩, តម្កល់ទុកជាឯកសារជាមួយអង្គការលើកលែងទោសអន្តរជាតិ។

គោលនយោបាយគ្រឿងញៀនកម្ពុជា ស្ថិតនៅលើផ្លូវបំបែកដ៏សំខាន់មួយ។ ការជាប់ទាក់ទងនាពេលបច្ចុប្បន្ននៅក្នុងគោលនយោបាយ និងការអនុវត្តរបស់រដ្ឋាភិបាល អាចថាតើត្រូវដោះស្រាយ ដើម្បីភាពពេញចិត្តខាងសិទ្ធិមនុស្ស និងវិធីសាស្ត្រផ្តោតលើសុខភាពសាធារណៈ ដែលសង្កត់ធ្ងន់លើសិទ្ធិទទួលបានសុខភាពរបស់មនុស្ស ដែលប្រើប្រាស់គ្រឿងញៀន ឬក៏ប្រើជម្រើសមួយទៀត តាមរយៈការផ្តាប់ចិត្តចំពោះគោលនយោបាយបែបមហន្តរាយនៃការឃុំខ្លួន ការកាត់ទោសព្រហ្មទណ្ឌ អំពើពុករលួយ និងការរំលោភបំពានដ៏ធំធេង ដែលជាការសន្យាគ្រាន់តែដើម្បីធ្វើឱ្យបញ្ហាសង្គមកាន់តែធ្ងន់ធ្ងរឡើងឬយ៉ាងណា។

ដោយមើលឃើញពីការបរាជ័យជាក់ស្តែងនៃយុទ្ធនាការប្រឆាំងគ្រឿងញៀន អង្គការលើកលែងទោសអន្តរជាតិ អំពាវនាវឱ្យមានការពិនិត្យឡើងវិញជាបន្ទាន់ នូវវិធីសាស្ត្ររបស់រដ្ឋាភិបាលកម្ពុជាចំពោះគ្រឿងញៀន។ ជំហានលើកទឹកចិត្តដែលត្រូវបានអនុវត្តដោយធាតុនានានៅក្នុងរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងសុខាភិបាល ត្រូវតែទទួលបានអាទិភាពនិងការគាំទ្រ ហើយការអនុវត្តន៍បែបរំលោភបំពាន និងបរាជ័យពីអតីតកាល ត្រូវបានកំណត់នៅក្នុងប្រវត្តិសាស្ត្រ។

ដើម្បីឱ្យប្រទេសកម្ពុជាប្រកាន់យកនូវវិធីសាស្ត្រប្រកបដោយប្រសិទ្ធភាព ផ្អែកលើភស្តុតាង និងអនុលោមតាមសិទ្ធិមនុស្ស ពាក់ព័ន្ធនឹងគ្រឿងញៀន វាចាំបាច់ណាស់ដែលមណ្ឌលឃុំឃាំងគ្រឿងញៀនដោយបង្ខំទាំងអស់ ត្រូវបិទទ្វារជាបន្ទាន់ និងជាអចិន្ត្រៃយ៍ ហើយមនុស្សដែលត្រូវបានគេឃុំឃាំងនៅទីនោះ ត្រូវតែដោះលែង ដោយផ្តល់ឱ្យពួកគេនូវសេវាសុខភាពនិងសង្គមកិច្ចគ្រប់គ្រាន់ ដែលអាចរកបានតម្រូវការរបស់ពួកគេ។ ម្យ៉ាងវិញទៀត ដើម្បីការពារឱ្យបានពេញលេញនូវសិទ្ធិរបស់អ្នកដែលប្រើប្រាស់គ្រឿងញៀន និងសហគមន៍ដែលរងផលប៉ះពាល់ដទៃទៀត អាជ្ញាធរគួរតែធ្វើចលនាដោយគ្មានការពន្យាពេលឆ្ពោះទៅរកការលុបចោលការដាក់ជាបទឧក្រិដ្ឋនៃការប្រើប្រាស់និងការកាន់កាប់គ្រឿងញៀន សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន។

ដៃគូអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា គួរតែប្រឆាំងនឹង “ការស្តារនីតិសម្បទា” គ្រឿងញៀនបែបបង្ខំ ហើយប្រឆាំងនឹងការដាក់ជាបទឧក្រិដ្ឋនៃការប្រើប្រាស់និងការកាន់កាប់គ្រឿងញៀនសម្រាប់ប្រើផ្ទាល់ខ្លួន ហើយប្រសិនបើអាជ្ញាធរកម្ពុជាអនុវត្តសកម្មភាពប្រកបដោយអត្ថន័យដើម្បីធ្វើកំណែទម្រង់គោលនយោបាយគ្រឿងញៀនរបស់ខ្លួន - សូមផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់ការពង្រឹងនិងពង្រីកសេវាព្យាបាលគ្រឿងញៀនតាមសហគមន៍ និងសេវាកាត់បន្ថយគ្រោះថ្នាក់ និងគាំទ្រការផ្លាស់ប្តូរឆ្ពោះទៅរកការលុបចោលនៃការដាក់ជាបទឧក្រិដ្ឋ។

# អនុសាសន៍

## ជូននាយករដ្ឋមន្ត្រី និង អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

1. សូមប្រកាសជាបន្ទាន់នូវការត្រួតពិនិត្យឡើងវិញដ៏ទូលំទូលាយស្តីពីយុទ្ធនាការប្រឆាំងគ្រឿងញៀន ដោយដាក់ចេញជាផែនការដឹកនាំយុទ្ធនាការនេះ ឱ្យស្របទៅនឹងច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដោយផ្តោតលើសិទ្ធិទទួលបានការថែរក្សាសុខភាព និងសិទ្ធិមនុស្សដទៃទៀត។
2. សូមបញ្ជាឱ្យបិទមណ្ឌលឃុំឃាំងគ្រឿងញៀននិងមណ្ឌលសង្គមកិច្ចបែបបង្ខំទាំងអស់ ជាបន្ទាន់និងជាអចិន្ត្រៃយ៍ និងធានាថារាល់ការព្យាបាលនិងការស្តារនីតិសម្បទាគ្រឿងញៀននៅកម្ពុជា គឺផ្អែកលើភស្តុតាង ដោយការស្ម័គ្រចិត្ត និងមានកិច្ចការពារដោយមានការយល់ព្រមតាមផ្តល់ព័ត៌មានជាមុន។
3. សូមផ្តល់អាទិភាពដល់ការថែទាំសុខភាពនិងការព្យាបាលគ្រឿងញៀនតាមសហគមន៍ និងធានាថា សេវានិងទីកន្លែងព្យាបាលគ្រឿងញៀនតាមសហគមន៍ ដំណើរការស្របតាមភស្តុតាងវិទ្យាសាស្ត្រ និងបទដ្ឋានសិទ្ធិមនុស្ស។
4. សូមធានាថា កម្មវិធីតាមសហគមន៍ ត្រូវតែទទួលបាននូវមូលនិធិ និងការកែលំអគ្រប់គ្រាន់ដោយមានការគាំទ្រផ្នែកបច្ចេកទេសពីអង្គការសហប្រជាជាតិ និងអង្គការសង្គមស៊ីវិល។

5. សូមផ្តួចផ្តើមដំណើរការនៃការអនុវត្តអនុសាសន៍នៃការពិនិត្យឡើងវិញជាសកលតាមកាលកំណត់លេខ ១១០.១៥៦ ដោយលប់ចោលការដាក់ជាបទឧក្រិដ្ឋ នូវការប្រើប្រាស់ និងកាន់កាប់គ្រឿងញៀន សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន និងលើកកម្ពស់សេវាកម្មកាត់បន្ថយគ្រោះថ្នាក់។
6. បណ្តុះបណ្តាលភ្នាក់ងារប្រតិបត្តិច្បាប់ក្នុងការកាត់បន្ថយគ្រោះថ្នាក់ និងធានាថាពួកគេមិនផ្តោតគោលដៅលើកន្លែងផ្តល់សេវាសុខភាពនិងសេវាកាត់បន្ថយគ្រោះថ្នាក់ ដែលជាយុទ្ធសាស្រ្តសម្រាប់ប្រតិបត្តិការពង្រឹងការប្រើគ្រឿងញៀននោះឡើយ។
7. សូមបោះបង់ចោលផែនការបច្ចុប្បន្នក្នុងការសាងសង់មជ្ឈមណ្ឌលព្យាបាលគ្រឿងញៀនជាតិថ្មីនៅខេត្តព្រះសីហនុ និងសូមធានាថា គ្រប់កន្លែងព្យាបាលទាំងអស់នាពេលអនាគត ត្រូវតែដំណើរការស្របតាមគោលការណ៍ណែនាំអន្តរជាតិ សម្រាប់ការព្យាបាល និងស្តារនីតិសម្បទាគ្រឿងញៀន។
8. សូមបញ្ចូលអ្នកប្រើប្រាស់គ្រឿងញៀន និងសហគមន៍ដែលរងផលប៉ះពាល់ផ្សេងទៀត រួមទាំងអង្គការសង្គមស៊ីវិលនិងអ្នកជំនាញផ្នែកសុខភាព សេវាកម្មសង្គម និងវិស័យពាក់ព័ន្ធដទៃទៀត ក្នុងការរចនាការអនុវត្ត ការពិនិត្យតាមដាន និងវាយតម្លៃលើច្បាប់និងគោលនយោបាយត្រួតពិនិត្យគ្រឿងញៀន ដែលមានឥទ្ធិពលលើពួកគេ។
9. សូមធានាឱ្យមានបរិយាកាសសុវត្ថិភាពនិងអំណោយផល សម្រាប់អ្នកការពារសិទ្ធិមនុស្សដែលតស៊ូមតិ ធ្វើកំណែទម្រង់ច្បាប់និងគោលនយោបាយគ្រឿងញៀន ដោយអនុញ្ញាតឱ្យពួកគេអាចដឹកនាំធ្វើសកម្មភាពរបស់ពួកគេ ដោយគ្មានការភ័យខ្លាចចំពោះការដាក់ទណ្ឌកម្ម ការសងសឹក ឬការបំភិតបំភ័យ។
10. សូមដោះស្រាយបុព្វហេតុនិងកត្តាសេដ្ឋកិច្ចសង្គម ដែលអាចបង្កើនហានិភ័យនៃការប្រើប្រាស់គ្រឿងញៀន ឬដែលនាំឱ្យប្រជាពលរដ្ឋ ចូលរួមក្នុងការធ្វើពាណិជ្ជកម្មគ្រឿងញៀន រួមមានសុខភាពមិនល្អ ការបដិសេធការអប់រំ ភាពអត់ការងារធ្វើ កង្វះផ្ទះសម្បែង ភាពក្រីក្រ និងការរើសអើង។
11. សូមដាក់ចេញនូវវិធានការការពារយេនឌ័រ និងសេដ្ឋកិច្ច-សង្គម ដើម្បីធានាថា ច្បាប់និងគោលនយោបាយត្រួតពិនិត្យគ្រឿងញៀន រួមចំណែកដល់ការយកឈ្នះលើប្រភពរចនាសម្ព័ន្ធដែលងាយរងគ្រោះ ការមាក់ងាយ និងការរើសអើង ដែលប៉ះពាល់ដល់អ្នកដែលប្រើប្រាស់គ្រឿងញៀន ឬអ្នកដែលចូលរួមក្នុងជំនួញគ្រឿងញៀន ជាពិសេស ស្រ្តីនិងអ្នកដែលស្ថិតនៅក្នុងសហគមន៍ ដែលងាយរងការម៉ាក់ងាយនិងដែលក្រីក្រ។

## ជូនក្រសួងយុត្តិធម៌ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

12. សូមផ្តើមដំណើរការពិនិត្យ និងធ្វើវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ ២០១២ ដើម្បីហាមឃាត់យ៉ាងដាក់លាក់ចំពោះការព្យាបាលនិងឃុំខ្លួនក្នុងមណ្ឌលព្យាបាលគ្រឿងញៀនដោយបង្ខំ។
13. សូមចាត់នីតិវិធីពិនិត្យឡើងវិញនូវការផ្តន្ទាទោសនិងការកាត់ទោសចំពោះបទល្មើស ដែលទាក់ទងនឹងការប្រើប្រាស់ និងការកាន់កាប់គ្រឿងញៀន សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ហើយនៅពេលដែលសមស្រប សូមដកហូតការធ្វើដំណើរ ឬកាត់បន្ថយពិរុទ្ធភាព និង/ឬការវិនិច្ឆ័យទោសដែលមានស្រាប់។
14. សូមជៀសវាងការដាក់ពន្ធនាគារលើកុមារ ឬទម្រង់នៃការដកហូតសិទ្ធិសេរីភាព ដោយដោយសារតែការប្រើប្រាស់ ឬការកាន់កាប់គ្រឿងញៀន។ ការដកហូតសិទ្ធិសេរីភាពរបស់កុមារចំពោះបទល្មើសទាក់ទងនឹងគ្រឿងញៀន គួរតែជាមធ្យោបាយចុងក្រោយ និងសម្រាប់រយៈពេលសមស្របដ៏ខ្លីបំផុត ហើយត្រូវតែស្ថិតនៅក្នុងទីតាំងមួយដែលសមស្របជាពិសេសទៅនឹងតម្រូវការរបស់ពួកគេ និងដាក់ដាច់ដោយឡែកពីមនុស្សពេញវ័យ។
15. សូមជំរុញការប្រើប្រាស់ការកាត់ទោសដោយមិនបាច់ឃុំខ្លួន មាតាបិតា ឬអ្នកអាណាព្យាបាលដែលមានកុមារពឹងអាស្រ័យ ដោយគិតគូរដល់ផលប្រយោជន៍ល្អបំផុតរបស់កុមារ និងដល់ស្រ្តីមានផ្ទៃពោះ។
16. សូមរៀបចំនិងផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ចៅក្រម ស្តីពីការសន្មតថាគ្មានទោស សិទ្ធិមានសេរីភាព និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដទៃទៀត។
17. សូមធានាថា ចៅក្រមដឹងអំពីកាតព្វកិច្ចរបស់ខ្លួន ក្នុងការចេញបញ្ជាឃុំខ្លួនបណ្តោះអាសន្នសម្រាប់តែជាវិធានការចុងក្រោយប៉ុណ្ណោះ ហើយនៅពេលចាំបាច់ ការដោះលែងគួរតែធ្វើដោយកម្រិតការចាកចេញក្រៅប្រទេសមុនការវិនិច្ឆ័យទោស ការមិនបង្កគ្រោះថ្នាក់ដល់អ្នកដទៃ ឬការមិនជ្រៀតជ្រែកដល់ភស្តុតាង ឬការស៊ើបអង្កេត។
18. សូមធានាថា គោលនយោបាយថ្មីស្តីពីជំនួយផ្នែកច្បាប់ ដែលស្ថិតក្នុងសេចក្តីព្រាង ផ្តល់នូវជំនួយផ្នែកច្បាប់ឥតគិតថ្លៃ សម្រាប់ជនជាប់ចោទទាំងអស់ ដែលមិនអាចមានលទ្ធភាពជួល

មេធាវីតាមការជ្រើសរើសរបស់ពួកគេ នៅពេលប្រឈមនឹងការជាប់ទោសដែលអាចកើតមាន។

## ជូនក្រសួងមហាផ្ទៃ

19. សូមប្រកាសនិងផ្សព្វផ្សាយដល់មន្ត្រីប្រតិបត្តិច្បាប់ទាំងអស់ជាបន្ទាន់ នូវសេចក្តីជូនដំណឹងថាគ្មានជនណាដែលប្រើប្រាស់គ្រឿងញៀនគួរត្រូវបានចាប់ខ្លួន ឬឃុំខ្លួនដោយឈរលើមូលដ្ឋាននៃការប្រើប្រាស់គ្រឿងញៀន ការកាន់កាប់ ឬញៀនគ្រឿងញៀននោះទេ។
20. សូមបណ្តុះបណ្តាលប៉ូលិសនិងមន្ត្រីប្រតិបត្តិច្បាប់ស្តីពីគោលការណ៍កាត់បន្ថយគ្រោះថ្នាក់ និងលើកកម្ពស់ការចូលរួមបែបស្ថាបនា និងភាពជាដៃគូរវាងមន្ត្រីប្រតិបត្តិច្បាប់ និងអ្នកផ្តល់សេវាសុខភាព ជុំវិញបញ្ហាសុខភាពនិងបញ្ហាសិទ្ធិមនុស្សដទៃទៀត។
21. សូមបើកការស៊ើបអង្កេតជាបន្ទាន់និងមិនលំអៀង លើការចោទប្រកាន់ពីការធ្វើទារុណកម្មនិងការប្រព្រឹត្តមិនត្រឹមត្រូវផ្សេងទៀត ដែលប្រព្រឹត្តដោយមន្ត្រីប៉ូលិសក្នុងករណីពាក់ព័ន្ធគ្រឿងញៀន ហើយនាំអ្នកដែលទទួលខុសត្រូវទាំងអស់ ទៅរកយុត្តិធម៌ ក្នុងអង្គជំនុំជម្រះដោយយុត្តិធម៌។
22. សូមធានាថា មនុស្សទាំងអស់ដែលជាប់ឃុំក្នុងពន្ធនាគារកម្ពុជា ត្រូវទទួលបានទីធ្លាគេងគ្រប់គ្រាន់ មានហាត់ប្រាណ អាហារបំប៉ន ទឹកស្អាត និងអនាម័យស្របតាមច្បាប់ណែលសិនម៉ាន់ដេឡាសម្រាប់ការប្រព្រឹត្តចំពោះអ្នកទោស។
23. សូមធានាថា មានការផ្តល់ការព្យាបាលឯកទេសជូនស្ត្រីមានផ្ទៃពោះ ទារក និងម្តាយដែលកំពុងបំបៅដោះកូន ដែលត្រូវបានគេដកហូតសេរីភាពស្របតាមបទដ្ឋានអន្តរជាតិ។
24. សូមធានាថា អង្គការសង្គមស៊ីវិលឯករាជ្យ ត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការដោយសេរីនិងដោយគ្មានការភ័យខ្លាចនៃការសងសឹក និងធានាថា ពួកគេមានសិទ្ធិចូលទៅកាន់កន្លែងឃុំឃាំងដោយគ្មានការរឹតត្បិត។
25. សូមទទួលស្គាល់យ៉ាងច្បាស់អំពីភាពស្របច្បាប់របស់អ្នកការពារសិទ្ធិមនុស្សទាំងអស់ និងគាំទ្រដល់ការងាររបស់ពួកគេជាសាធារណៈ ដោយទទួលស្គាល់តួនាទីពិសេសនិងសំខាន់របស់ពួកគេ ក្នុងការជំរុញលើកស្ទួយសិទ្ធិមនុស្ស។

## ជូនក្រសួងសុខាភិបាល

26. សូមបង្កើនច្រកចេញចូលទទួលសេវាសុខភាពនិងសេវាសង្គម ដើម្បីកាត់បន្ថយហានិភ័យនិងគ្រោះថ្នាក់ ដែលទាក់ទងនឹងការប្រើប្រាស់គ្រឿងញៀន មានជាអាទិ៍ ការការពារ ព័ត៌មាន ការកាត់បន្ថយគ្រោះថ្នាក់ សេវាព្យាបាលដោយស្ម័គ្រចិត្ត និងការស្តារនីតិសម្បទា ដែលជាកន្លែងដែលមានការចង្អុលបង្ហាញខាងវេជ្ជសាស្ត្រ និងឈរលើមូលដ្ឋានមិនរើសអើង រួមទាំងនៅក្នុងពន្ធនាគារ និងស្ថានភាពផ្សេងទៀត ជាកន្លែងដែលមនុស្សត្រូវបានដកហូតសេរីភាពរបស់ពួកគេ។
27. សូមធានាថា ការកាត់បន្ថយគ្រោះថ្នាក់ សេវាព្យាបាល និងសេវាស្តារនីតិសម្បទា អាចរកបាន អាចទទួលយកបាន និងងាយស្រួលចូលទៅទទួលយកសម្រាប់អ្នករាល់គ្នា ដោយមិនរើសអើង និងសូមធានាថា សេវាមានគុណភាពល្អ។ នេះមានន័យថា ត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះសេចក្តីត្រូវការរបស់ជនដែលងាយរងការម៉ាក់ងាយបំផុត និងចំពោះតម្រូវការជាក់លាក់របស់ស្ត្រី កុមារ និងមនុស្សវ័យជំទង់។
28. សូមធានាថា កម្មវិធីព្យាបាលនិងស្តារនីតិសម្បទាគ្រឿងញៀន សម្រាប់អ្នកដែលប្រើប្រាស់គ្រឿងញៀន គឺផ្អែកលើភស្តុតាង មានការស្ម័គ្រចិត្ត និងមានការការពារដោយការយល់ព្រមតាមរយៈព័ត៌មានដែលដឹងជាមុន។ កម្មវិធីបែបនេះ ត្រូវតែផ្តល់វិធានការណ៍ការពារសិទ្ធិរបស់បុគ្គលទាំងឡាយ- ដែលជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ក្តី - មិនទាន់អាចផ្តល់ការយល់ព្រម។
29. សូមផ្តល់សេវាកាត់បន្ថយគ្រោះថ្នាក់ សេវាព្យាបាលនិងការស្តារនីតិសម្បទា ក្នុងបរិយាកាសសមស្របសម្រាប់ស្ត្រីនិងកុមារីដែលប្រើប្រាស់គ្រឿងញៀន មានជាអាទិ៍ការផ្តល់សេវារួមបញ្ចូលគ្នានៃសេវាថែទាំសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ ព័ត៌មាននិងសេវាកម្ម និងកន្លែងថែទាំកុមារ ដែលឆ្លើយតបទៅនឹងតម្រូវការជាក់លាក់ខាងយ៉េនឌ័រដទៃទៀត។
30. សូមធ្វើតាមការអនុវត្តន៍ល្អបំផុតជាអន្តរជាតិ សម្រាប់ការរៀបចំនិងអនុវត្តយុទ្ធនាការបង្ការដើម្បីណែនាំអំពីអន្តរាគមន៍និងគោលនយោបាយផ្អែកលើភស្តុតាងផ្សេងៗគ្នា ដោយផ្អែកលើអាយុក្រុមគោលដៅ កម្រិតហានិភ័យ និងបរិយាកាសដែលយុទ្ធនាការ នឹងត្រូវអនុវត្ត។
31. សូមបង្កើនការបណ្តុះបណ្តាលដល់បុគ្គលិកមណ្ឌលព្យាបាលគ្រឿងញៀនតាមសហគមន៍និងកែលម្អកន្លែងព្យាបាល និងការផ្តល់ផ្នែកវេជ្ជសាស្ត្រដល់កន្លែងដែលមានស្រាប់។

32. សូមធានាថា សេវាព្យាបាលគ្រឿងញៀនតាមសហគមន៍ ត្រូវបានចុះផ្សាយនិងផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅក្នុងសហគមន៍មូលដ្ឋាននិងតាមរយៈប្រព័ន្ធផ្សព្វផ្សាយ។
33. សូមពង្រីកសេវាកាត់បន្ថយគ្រោះថ្នាក់ រួមទាំងការផ្លាស់ប្តូរម្ជុលនៅតាមខេត្ត ដែលរាយការណ៍មកថាមានកំរិតខ្ពស់នៃការប្រើប្រាស់គ្រឿងញៀនដោយចាក់នឹងម្ជុល។
34. សូមផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីប៉ូលីស ស្តីពីការកាត់បន្ថយគ្រោះថ្នាក់ និងអន្តរាគមន៍លើការប្រើគ្រឿងញៀនហួសកម្រិត ដោយមានជំនួយពីទីភ្នាក់ងារអង្គការសហប្រជាជាតិនិងអង្គការក្រៅរដ្ឋាភិបាល ដែលពាក់ព័ន្ធ និងនៅពេលដែលសមស្រប។

## ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអាជ្ញាធរខេត្ត - ក្រុង

35. សូមបញ្ឈប់សកម្មភាពបោសតាមដងផ្លូវនិងសកម្មភាព "កែលម្អទីក្រុង" ដែលពាក់ព័ន្ធនឹងការចាប់ខ្លួនតាមអំពើចិត្តលើបុគ្គលដែលសង្ស័យពីការប្រើប្រាស់គ្រឿងញៀន ជនអនាថា អ្នករកស៊ីផ្លូវភេទ និងក្រុមដែលងាយរងការម៉ាក់ងាយផ្សេងទៀត។
36. សូមបញ្ឈប់ការអនុវត្តការធ្វើតេស្តរកសារធាតុញៀនដោយបង្ខំ លើមនុស្សដែលត្រូវបានគេចាប់ខ្លួនក្នុងការឆ្មក់ចូលទាក់ទងគ្រឿងញៀន និងបោសសម្អាតតាមដងផ្លូវ និងសូមធានាថាការធ្វើតេស្តគ្រឿងញៀនណាមួយ អាចធ្វើទៅបានទាល់តែមានការយល់ព្រមដោយទទួលបានព័ត៌មានជាមុន និងត្រូវតែអនុវត្តក្នុងមធ្យោបាយមួយ ដែលមិនមានការរើសអើងមានតម្លាភាពនិងយ៉ាងពេញលេញ។
37. សូមបិទចោលជាបន្ទាន់និងជាអចិន្ត្រៃយ៍ នូវរាល់កិច្ចការសង្គមកិច្ច និងមណ្ឌលឃុំឃាំងគ្រឿងញៀនដោយបង្ខំទាំងអស់ និងសូមធានាថា ប្រជាពលរដ្ឋដែលជាប់ឃុំខ្លួននៅទីនោះ ត្រូវបានដោះលែងជាបន្ទាន់ ដោយមានការផ្គត់ផ្គង់គ្រប់គ្រាន់នៃសេវាសុខភាពនិងសង្គមកិច្ច ដែលមានសម្រាប់ពួកគេតាមតម្រូវការ។
38. សូមធានាថា អ្នកឃ្លាំមើលឯករាជ្យ ពីអង្គការសហប្រជាជាតិ និងអង្គការសង្គមស៊ីវិល មានសិទ្ធិចេញចូលទៅកាន់មណ្ឌលឃុំឃាំងទាំងអស់យ៉ាងពេញលេញនិងគ្មានការរារាំង។

## ជូនក្រសួងអប់រំ យុវជន និងកីឡា

39. សូមធានាថា សាកលវិទ្យាល័យនៅកម្ពុជាផ្តល់នូវសញ្ញាប័ត្រ និងកម្មវិធីស្រាវជ្រាវគ្រប់គ្រាន់ក្នុងការងារសង្គម ការផ្តល់ប្រឹក្សាយោបល់ ចិត្តវិទ្យា និងការញៀនគ្រឿងញៀន ដើម្បីធានាបាននូវធនធានមនុស្ស ដែលចាំបាច់ដើម្បីគាំទ្រដល់វិធីសាស្ត្រផ្អែកលើភស្តុតាង។
40. សូមអនុវត្តយុទ្ធនាការផ្សព្វផ្សាយការយល់ដឹង ដែលអាចជួយកុមារបង្ការ ឬពន្យាពេលការប្រើប្រាស់គ្រឿងញៀនលើកដំបូង សម្រាប់គោលបំណងដែលមិនមែនជាវេជ្ជសាស្ត្រ និងសម្រាប់មនុស្សទាំងអស់ដែលប្រើគ្រឿងញៀន ដើម្បីជៀសវាងការវិវត្តនៃការញៀនសារធាតុញៀន និងកាត់បន្ថយគ្រោះថ្នាក់ទាក់ទងនឹងគ្រឿងញៀន។ អន្តរាគមន៍បង្ការ គួរតែរាប់បញ្ចូលកម្មវិធីអប់រំសាធារណៈ និងយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន ដែលច្រកបញ្ចូលព័ត៌មានស្តីពីកាត់បន្ថយគ្រោះថ្នាក់ និងផ្អែកលើភស្តុតាងវិទ្យាសាស្ត្រ ដែលពិពណ៌នាយ៉ាងត្រឹមត្រូវអំពីផលប៉ះពាល់នៃគ្រឿងញៀន រួមទាំងគ្រោះថ្នាក់ទាំងចំពោះអ្នកដែលប្រើប្រាស់គ្រឿងញៀន និងអ្នកដទៃទាំងឡាយ ដោយមិនមានការម៉ាក់ងាយ។
41. សូមបង្កើតយុទ្ធនាការបង្ការតាមគោលដៅ ដែលត្រូវបានបង្កើតឡើងជាពិសេសសម្រាប់កុមារនិងមនុស្សវ័យជំទង់ ទាំងនៅក្នុងកន្លែងអប់រំ និងទាំងនៅក្នុងមជ្ឈដ្ឋានខាងក្រៅសាលា ដូចជានៅតាមដងផ្លូវ និងទីតាំងពិធីជប់លៀង ក្នុងគោលបំណងផ្តល់សិទ្ធិអំណាចដល់ពួកគេ ធ្វើការសំរេចចិត្តដោយដឹងព័ត៌មានជាមុន អំពីអាកប្បកិរិយាផ្ទាល់ខ្លួនរបស់ពួកគេ និងសូមផ្តល់ព័ត៌មានឱ្យពួកគេអំពីកន្លែងដែលត្រូវស្វែងរកជំនួយ ប្រសិនបើពួកគេត្រូវការវា។

## ជូនដៃគូអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា

42. សូមប្រើប្រាស់គ្រប់បណ្តាញសហប្រតិបត្តិការដែលពាក់ព័ន្ធទាំងអស់ ដើម្បីលើកទឹកចិត្តដល់អាជ្ញាធរកម្ពុជា ឱ្យបិទមជ្ឈមណ្ឌល "ស្តារនីតិសម្បទា" គ្រឿងញៀនដោយបង្ខំទាំងអស់ និងធ្វើចលនាឆ្ពោះទៅរកការលុបចោលច្បាប់ដាក់ជាបទឧក្រិដ្ឋនៃការប្រើប្រាស់និងកាន់កាប់គ្រឿងញៀន។
43. សូមផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេស សម្រាប់ការផ្លាស់ប្តូររបស់ប្រទេសកម្ពុជា ទៅការព្យាបាលគ្រឿងញៀនដោយស្ម័គ្រចិត្តតាមសហគមន៍ និងការលុបចោលបញ្ញត្តិដាក់ជាបទ

ឧក្រិដ្ឋ តាមលក្ខខណ្ឌនៅចុងបញ្ចប់នៃរបបព្យាបាលគ្រឿងញៀនដែលមានលក្ខណៈបង្ខំរបស់ប្រទេសកម្ពុជា។

44. ធានាថា កម្មវិធីគាំទ្រផ្នែកហិរញ្ញវត្ថុនៅក្នុងវិស័យយុត្តិធម៌នៅកម្ពុជា នឹងពិចារណាពេញលេញលើ ភស្តុតាងទាំងអស់នៃការរំលោភសិទ្ធិមនុស្ស ដែលកើតឡើងនៅក្នុងប្រព័ន្ធតុលាការ និងកន្លែងឃុំឃាំង និងធានាថា កម្មវិធីជំនួយ មានការឆ្លើយតបចំពោះភស្តុតាង និងស្របតាមគោលដៅ ដើម្បីការពារអំពើហិង្សាពេលអនាគត។